មាត្រានៃសេចក្តីជំនឿ

នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

យើងខ្ញុំជឿដល់ព្រះ គឺព្រះវរបិតាដ៏គង់នៅអស់កល្បជានិច្ច និងដល់ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ហើយដល់ព្រះវិញ្ញាណបរិសុទ្ធ។

២ យើងខ្ញុំជឿថា មនុស្សទាំងអស់នឹងត្រូវទទួលទោសចំពោះអំពើបាបរបស់ខ្លួនផ្ទាល់ គឺមិនមែនចំពោះអំពើរំលងរបស់លោកអ័ដាមទេ។

៣ យើងខ្ញុំជឿថា តាមរយៈដង្វាយធួននៃព្រះគ្រីស្ទ នោះមនុស្សលោកទាំងអស់អាចបានសង្គ្រោះ ដោយសារការគោរពតាមក្រឹត្យវិន័យ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ។

៤ យើងខ្ញុំជឿថា គោលការណ៍ទីមួយ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អគឺ ៖ ទីមួយ សេចក្តីជំនឿជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ទីពីរ ការប្រែចិត្ត ទីបី បុណ្យជ្រមុជទឹក ដោយការពន្លិចសម្រាប់ការផ្តាច់បាប ទីបួន ការដាក់ដៃលើសម្រាប់អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ។

៥ យើងខ្ញុំជឿថា មនុស្សត្រូវតែបានហៅពីព្រះ ដោយការព្យាករណ៍ និងដោយការដាក់ដៃលើ ដោយអស់អ្នកណាដែលមានសិទ្ធិអំណាចដើម្បីនឹងផ្សាយដំណឹងល្អ ហើយប្រព្រឹត្តពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ។

៦ យើងខ្ញុំជឿចំពោះការរៀបចំដូចគ្នា ដូចដែលមាននៅក្នុងសាសនាចក្រពីអតីតកាល ដូចជា ពួកសាវក ពួកព្យាការី ពួកគ្រូគង្វាល ពួកគ្រូ ពួកគ្រូផ្សាយដំណឹងល្អជាដើម។

៧ យើងខ្ញុំជឿដល់អំណោយទានខាងភាសា ការព្យាករណ៍ វិវរណៈ ការនិមិត្ត ការប្រោសឲ្យជា ការបកប្រែភាសាជាដើម។

៨ យើងខ្ញុំជឿថា ព្រះគម្ពីរបរិសុទ្ធ គឺជាព្រះបន្ទូលនៃព្រះ បើសិនជាបានបកប្រែត្រឹមត្រូវ យើងខ្ញុំក៏ជឿដែរថា ព្រះគម្ពីរមរមនជាព្រះបន្ទូលនៃព្រះ។

៩ យើងខ្ញុំជឿចំពោះការណ៍ទាំងអស់ ដែលទ្រង់បានបើកសម្តែងមក និងការណ៍ទាំងអស់ ដែលទ្រង់បើកសម្តែងនៅពេលឥឡូវនេះ ហើយយើងខ្ញុំជឿថា ទ្រង់នឹងបើកសម្តែងនូវការណ៍ដ៏ធំ និងសំខាន់ៗជាច្រើន ដែលទាក់ទងទៅនឹងនគរនៃព្រះ។

១០ យើងខ្ញុំជឿចំពោះការប្រមូលដ៏ពិតប្រាកដនៃសាសន៍អ៊ីស្រាអែល និងចំពោះការសាងឡើងវិញនូវពូជទាំង១០អំបូរ ថាក្រុងស៊ីយ៉ូន (ក្រុងយេរូសាឡិមថ្មី) នឹងត្រូវបានស្ថាបនានៅលើទ្វីបអាមេរិក ថាព្រះគ្រីស្ទនឹងគ្រងរាជ្យនៅលើផែនដីផ្ទាល់ ហើយថាផែនដីនឹងបានផ្លាស់ប្តូរសារជាថ្មី ហើយនឹងទទួលសិរីល្អដ៏ប្រកបដោយភាពបរមសុខ។

១១ យើងខ្ញុំសូមអះអាងយកសិទ្ធិក្នុងការថ្វាយបង្គំព្រះដ៏មានមហិទ្ធិឫទ្ធិស្របតាមការណែនាំនៃសម្បជញ្ញៈរបស់យើងខ្ញុំ ហើយសូមបណ្តោយឲ្យមនុស្សទាំងអស់មានសិទ្ធិដូចគ្នា ចូរឲ្យគេថ្វាយបង្គំតាមរបៀបណា នៅទីណា ឬអ្វីក៏ដោយដែលគេប្រាថ្នា។

១២ យើងខ្ញុំជឿចំពោះការនៅក្រោមអំណាចស្តេច ប្រធានាធិបតី អ្នកគ្រប់គ្រង និងចៅក្រមទាំងឡាយ ក្នុងការគោរព ការប្រតិបត្តិ និងការគាំទ្រច្បាប់។

១៣ យើងខ្ញុំជឿលើការប្រព្រឹត្តដោយទៀងត្រង់ ត្រឹមត្រូវ បរិសុទ្ធ សប្បុរស គុណធម៌ ហើយលើការធ្វើល្អដល់មនុស្សទាំងអស់ ពិតមែនហើយ យើងខ្ញុំអាចនិយាយបានថា យើងខ្ញុំដើរតាមសេចក្តីដាស់តឿនរបស់ប៉ុល — យើងខ្ញុំជឿដល់អ្វីៗទាំងអស់ យើងខ្ញុំសង្ឃឹមដល់អ្វីៗទាំងអស់ យើងខ្ញុំបានទ្រាំទ្រអ្វីៗជាច្រើន ហើយសង្ឃឹមថានឹងអាចទ្រាំទ្រអ្វីៗទាំងអស់បានដែរ។ ហើយបើសិនជាមានអ្វីណាមួយ ដែលប្រកបដោយគុណធម៌ គួរស្រឡាញ់ ឬឈ្មោះល្អ ឬក៏គួរឲ្យសរសើរ នោះយើងខ្ញុំស្វែងរករបស់ផងទាំងនេះហើយ។

យ៉ូសែប ស្ម៊ីធ.

Unofficial poster layout of the text published on churchofjesuschrist.org. Not an official publication of The Church of Jesus Christ of Latter-day Saints. Generated by Urim, urim.samuelbaird.com